**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

លេខ ....................... .រ.ស.

**សូមជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**តាមរយៈ** : សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា

**កម្មវត្ថុ** : សុំដាក់សំណួរដល់រាជរដ្ឋាភិបាលអំពីប្រតិកម្មរបស់រាជរដ្ឋាភិបាលចំពោះសេចក្តីសំរេច ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ របស់សភាអឺរ៉ុប "ស្តីពីកម្ពុជា ជាពិសេសករណី សម រង្ស៊ី" ។

**យោង** : -មាត្រា៩៦ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-សេចក្តីសំរេច ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ របស់សភាអឺរ៉ុប "ស្តីពីកម្ពុជា ជាពិសេសករណី សម រង្ស៊ី" (ខ្លឹមសារដើមជាភាសាអង់គ្លេសភ្ជាប់មកជាមួយនេះ)

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំជាអ្នកតំណាងរាស្ត្រ ដូចមានរាយនាមខាងក្រោម សូមសួរទៅរាជរដ្ឋាភិបាលថា តើរាជរដ្ឋាភិបាលនឹងចាត់វិធានការយ៉ាងដូចម្តេចខ្លះ ឬធ្វើសេចក្តីសំរេចយ៉ាងដូចម្តេចខ្លះ ដើម្បីឆ្លើយតបទៅនឹងសំណើ និងអនុសាសន៍នៃសភាអឺរ៉ុប ដែលចង់ឃើញដំណោះស្រាយចំពោះបញ្ហានយោបាយមួយចំនួននៅប្រទេសកម្ពុជា ស្របទៅនឹងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ពិតប្រាកដ ?

សហភាពអឺរ៉ុប (European Union) តាមរយៈគណៈកម្មាធិការអឺរ៉ុប (European Commission) គឺជាស្ថាប័នអន្តរជាតិមួយដ៏សំខាន់បំផុតដែលផ្តល់ជំនួយយ៉ាងធំធេងជូនប្រទេសកម្ពុជា ។ គណៈកម្មាធិការអឺរ៉ុបនេះ គឺធ្វើសេចក្តីសំរេច និងប្រព្រឹត្តការងាររបស់ខ្លួនក្រោមការណែនាំ និងការតាមដានរបស់សភាអឺរ៉ុប (European Parliament) ។

ក្នុងសេចក្តីសំរេចរបស់ខ្លួន ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ សភាអឺរ៉ុបបានស្នើជាពិសេស ឲ្យរាជរដ្ឋាភិបាលកម្ពុជា "ធ្វើការកែទម្រង់ផ្នែកនយោបាយ និងកែទម្រង់ស្ថាប័នមួយចំនួន ជាពិសេស ប្រព័ន្ធយុត្តិធម៌ ដើម្បីកសាងនីតិរដ្ឋមួយដែលមានលក្ខណៈប្រជាធិបតេយ្យ ហើយមានការគោរពសិទ្ធិសេរីភាពជាមូលដ្ឋាន" ។ ម៉្យាងវិញទៀត សភាអឺរ៉ុបក៏បានស្នើផងដែរឲ្យរាជរដ្ឋាភិបាល "រៀបចំកម្មវិធី និងប្រតិទិនដើម្បីអនុវត្តអនុសាសន៍របស់លោកតំណាងពិសេស នៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា" ដែលមានចែងក្នុងរបាយការណ៍របស់លោក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ ដែលសង្កត់ធ្ងន់លើ "ការជ្រៀតជ្រែកពីក្រៅមកលើប្រព័ន្ធតុលាការ" ។

សូមបញ្ជាក់ថា ក្រុមនយោបាយទាំងអស់ដែលតំណាងឲ្យតំណាងរាស្ត្រ ៧៣៦ រូប មកពី ២៧ ប្រទេស នៃទ្វីបអឺរ៉ុបទាំងមូល បានបោះឆ្នោតជាឯកច្ឆន្ទ អនុម័តសេចក្តីសំរេចរបស់សភាអឺរ៉ុប ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ ខាងលើនេះ ។

តើរាជរដ្ឋាភិបាលនឹងប្រកាន់គោលជំហរយ៉ាងដូចម្តេច ដើម្បីរក្សាជំនួយពីសហភាពអឺរ៉ុប និងរក្សាកិត្តិយសនៃប្រទេសកម្ពុជាដែលកំពុងស្ថិតក្រោមការឃ្លាំមើលនៃសហគមន៍អន្តរជាតិ ?

អាស្រ័យដូចបានជម្រាបជូនខាងលើ យើងខ្ញុំសង្ឃឹមថា រាជរដ្ឋាភិបាលនឹងឆ្លើយនូវសំណួររបស់យើងខ្ញុំឲ្យបានច្បាស់លាស់ តាមការគួរ ។

សូមសម្តេចនាយករដ្ឋមន្ត្រីទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រ អំពីយើងខ្ញុំ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០*

**ក្រុមអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី**

**បានឃើញ និងបញ្ជូនមក**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

"ដើម្បីពិនិត្យ"

*ភ្នំពេញ, ថ្ងៃទី………… ខែតុលា ឆ្នាំ២០១០*

**ប្រធានរដ្ឋសភា**

**<u>ចម្លងជូន</u> :**

- សម្តេចព្រះមហាវីរក្សត្រ
- ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា